

massDOT
Massachusetts Department of Transportation
Highway Division

# គម្រោងផ្លាស់ប្តូរស្ពាន Rourke ៖
# កិច្ចប្រជុំសាធារណៈតាមអនឡាញ ថ្ងៃទី 7 ខែកុម្ភៈ ឆ្នាំ 2023

## តើអ្វីកំពុងកើតឡើង?

ក្រសួងដឹកជញ្ជូនរដ្ឋ Massachusetts (MassDOT) មានសេចក្តីរីករាយក្នុងការផ្តល់បច្ចុប្បន្នភាពអំពី គម្រោងផ្លាស់ប្តូរស្ពាន Rourke ។ ស្ពាន Rourke គឺជាការតភ្ជាប់ការដឹកជញ្ជូនដ៏សំខាន់មួយឆ្លងកាត់ទន្លេ Merrimack នៅក្នុងទីក្រុង Lowell ។ ស្ពាននេះចម្លងយានយន្តប្រហែល 27,000 គ្រឿងក្នុងមួយថ្ងៃ ។ ស្ពានចាស់ត្រូវបានកសាងក្នុងឆ្នាំ 1983 ជាស្ពានបណ្តោះអាសន្ន ។ សមត្ថភាពចម្លងយានយន្តរបស់ស្ពាននៅខ្វះចន្លោះ ហើយលក្ខណៈពិសេសរបស់ស្ពានសម្រាប់ទោចក្រយាន និងអ្នកថ្មើរជើងមិនឆ្លើយតបនឹងស្តង់ដារពហុមធ្យោបាយ និង ADA ទេ ។ វាកំពុងខិតជិតដល់ទីបញ្ចប់នៃជីវិតប្រើប្រាស់ដែលមានប្រយោជន៍របស់វា ហើយរចនាសម្ព័ន្ធរាយរងសម្រាប់ទ្រក៏កំពុងបង្ហាញសញ្ញានៃការទ្រុឌទ្រោមដែរ ។

## តើនេះនឹងមានផលប៉ះពាល់ដល់អ្នកយ៉ាងដូចម្តេចខ្លះ?

ចាប់តាំងពីកិច្ចប្រជុំលើកចុងក្រោយរបស់យើងមក MassDOT និងក្រុមការងារគម្រោងបាននិងកំពុងធ្វើការដើម្បីបំផុសគោលគំនិតដំបូងសម្រាប់ស្ពាននេះ ។ នៅក្នុងកិច្ចប្រជុំតាមអនឡាញនេះ ក្រុមការងារគម្រោង នឹងចែករំលែកគោលគំនិតទាំងនេះជាមួយសាធារណជនដើម្បីសុំយោបល់ត្រឡប់ និងគូសវាសជំហានបន្តបន្ទាប់ ។

**ពេលវេលា**
ថ្ងៃអង្គារ ទី 7 ខែកុម្ភៈ ឆ្នាំ 2023
ម៉ោង 6:00 ល្ងាច

**ចូលរួម**
www.mass.gov/orgs/highway-division/events

**ចូលទៅ** www.mass.gov/rourke-bridge-replacement-project **សម្រាប់ព័ត៌មានបន្ថែម ។**

កិច្ចប្រជុំនេះក៏អនុញ្ញាតសម្រាប់ជនពិការ និងអ្នកដែលមានភាពស្ទាត់ជំនាញខាងភាសាអង់គ្លេសនៅមានកម្រិតផងដែរ ។ MassDOT ផ្តល់ការរៀបចំសម្រួលសមរម្យ និង/ឬ ជំនួយផ្នែកភាសាដោយឥតគិតថ្លៃ តាមការស្នើសុំ និងសមស្រប ។ ដើម្បីស្នើសុំការរៀបចំសម្រួល ឬជំនួយផ្នែកភាសា សូមទាក់ទងមកប្រធានផ្នែកចម្រុះភាពរបស់ MassDOT និងមន្ត្រីទទួលបន្ទុកសិទ្ធិពលរដ្ឋ តាមទូរស័ព្ទ (857) 368-8580, ទូរសារ (857) 368-0602, លេខហៅបន្ត 7-1-1, ឬផ្ញើអ៊ីមែលមក MassDOT.CivilRights@dot.state.ma.us ។ សំណើគួរធ្វើឲ្យបានឆាប់តាមដែលអាចធ្វើទៅបានឲ្យបានមុនកិច្ចប្រជុំ ហើយសម្រាប់សេវាកម្មដែលពិបាករៀបចំជាង ដូចជា ភាសាសញ្ញា, CART ឬការបកប្រែភាសា ឬការបកប្រែផ្ទាល់មាត់ សំណើគួរធ្វើឡើងយ៉ាងតិចដប់ថ្ងៃនៃថ្ងៃធ្វើការ មុនពេលប្រជុំ ។

ការសាកសួរអំពីគម្រោងក៏អាចផ្ញើតាមរយៈវេបសាយរបស់គម្រោង៖ www.mass.gov/rourke-bridge-replacement-project
សូមបញ្ជូនរបាយការណ៍ជាលាយលក្ខណ៍អក្សរដែលទាក់ទងនឹងកិច្ចការទទួលរ៉ាប់រងដែលបានស្នើ មកកាន់៖ **Carrie A. Lavallee, P.E., ប្រធានវិស្វករ, MassDOT, 10 Park Plaza, Boston, MA 02116, Attention: HIGHWAY DEPARTMENT, PROJECT FILE NO. 607887**